**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ ០៣ សរ**

# សារាចរ

# ស្តីពី

# ការអនុវត្តន៍វិធានការអប់រំ ព្យាបាល និងស្តារនីតិសម្បទា អ្នកញៀនគ្រឿងញៀន

- ដោយពិនិតឃើញថា សភាពការណ៍ប្រើប្រាស់បំពានគ្រឿងញៀន ក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះការកើនឡើងគួរអោយកត់សំគាល់ក្នុងចំណោមកម្មករ ពលករ ពិសេសក្នុងស្រទាប់យុវវ័យដែលជានិន្នាការឈានទៅរកការបាត់បង់ធនធានមនុស្សប៉ះពាល់ដល់សេដ្ឋកិច្ច សង្គមកិច្ចរាំងស្ទះដំណើរការអភិវឌ្ឍន៍ ប្រទេសជាតិកង្វល់ចំពោះរាជរដ្ឋាភិបាល សហគមន៍ គ្រួសារព្រមទាំងបន្សល់ទុកនូវអ្នករងគ្រោះ ដោយសារគ្រឿងញៀនច្រើននាក់ដែលបច្ចុប្បន្នកំពុងត្រូវការសេវាជួយសង្គ្រោះព្យាបាល និងស្តារនីតិសម្បទាពីស្ថាប័នមានសមត្ថកិច្ច ។

- ចំពោះមុខសភាពការណ៍ដ៏គ្រោះថ្នាក់នេះ ដើម្បីរួមចំណែកអនុវត្តកម្មវិធីនយោបាយជាយុទ្ធសាស្ត្ររបស់រដ្ឋាភិបាល និងឈានទៅសំរេចបាននូវផែនការជាតិ ៥ ឆ្នាំ ស្តីពីការត្រួតពិនិត្យគ្រឿងញៀនរបស់អាជ្ញាធរជាតិប្រឆាំង គ្រឿងញៀន រាជរដ្ឋាភិបាលសូមធ្វើការណែនាំដល់គ្រប់ក្រសួង និងស្ថាប័នមានសមត្ថកិច្ចពាក់ព័ន្ធនិងមូលដ្ឋាន គ្រប់ខេត្ត-ក្រុង ត្រូវយកចិត្តទុកដាក់អនុវត្តអោយបានម៉ឺងម៉ាត់នូវវិធានការចាំបាច់មួយចំនួនដូចខាងក្រោម :

១. អាជ្ញាធរមូលដ្ឋាន ខេត្ត-ក្រុង ជាពិសេសខេត្ត-ក្រុងដែលមានអ្នកញៀនគ្រឿងញៀនច្រើន ត្រូវខិតខំដោះស្រាយរកទីតាំងរៀបចំមជ្ឈមណ្ឌលសំរាប់ទទួលព្យាបាល និងស្តានីតិសម្បទាអ្នកញៀនគ្រឿងញៀនអោយបានមួយកន្លែង ដោយសហការជាមួយក្រសួង និងស្ថាប័នជំនាញពាក់ព័ន្ធ។ ជាមួយនេះត្រូវបំផុសលើកទឹកចិត្តអោយមានការចូលរួមពីសហគមន៍គ្រួសារ និងអតីតអ្នកញៀនគ្រឿងញៀនសំរាប់ឈានទៅបង្កើតសហគមន៍គ្មានគ្រឿងញៀនមួយជាគំរូ ។

២. ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និង អាជ្ញាធរខេត្ត-ក្រុងដើម្បីគ្រប់គ្រងមជ្ឈមណ្ឌលស្តារនីតិសម្បទា អ្នកញៀនគ្រឿងដែលបានបង្កើត និងកំពុង ដំណើរការនៅទីក្រុងភ្នំពេញ និងនៅតាមខេត្ត-ក្រុងនានា ។

៣. ក្រសួងសុខាភិបាល ត្រូវខិតខំបង្កើតផ្នែកជំនាញព្យាបាលអ្នកញៀនគ្រឿងញៀនថ្នាក់ជាតិ នៅទីក្រុង ភ្នំពេញ និងត្រូវរៀបចំអោយមានសេវាពិគ្រោះយោបល់នៅតាមមន្ទីពេទ្យបង្អែកខេត្ត-ក្រុង និងស្រុកសំរាប់ ផ្តល់ប្រឹក្សា និងព្យាបាលអ្នកញៀនគ្រឿងញៀន ដែលគ្រួសារអាណាព្យាបាល បានបញ្ជូនទៅកាន់មន្ទីពេទ្យព្រម ទាំងបង្កើតបទដ្ឋានបច្ចេកទេសត្រួតពិនិត្យសេវាព្យាបាលអ្នកញៀនគ្រឿងញៀននៅតាមមជ្ឈមណ្ឌលក្នុង សហគមន៏ និង លុបបំបាត់កន្លែងព្យាបាលជំងឺដែលមិនមានច្បាប់អនុញ្ញាតពីក្រសួងសុខាភិបាល ។

៤. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀនផ្អែកតាមតម្រូវការថវិកាសំរាប់កសាងមជ្ឈមណ្ឌល និងថវិកាចំណាយចរន្តសំរាប់គាំទ្រសេវាអប់រំ ព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿង ត្រូវបញ្ចូលគំរោងថវិកា ទាំងនោះទៅក្នុងគំរោងថវិកាប្រចាំឆ្នាំរបស់ក្រសួងមហាផ្ទៃហើយការផ្តល់ថវិកាត្រូវធ្វើឡើងតាមរយៈក្រសួង មហាផ្ទៃ ដែលជាអាណាប័កដើមខ្សែ ។

៥. ក្រសួងមហាផ្ទៃ ក្រសួងការពារជាតិ ក្រសួងយុត្តិធម៌ ទន្ទឹមនិងការពង្រីកវិធានការទប់ស្កាត់ ការផលិត ការចរាចរហូចូលគ្រឿងញៀនខុសច្បាប់ និងការប្រើប្រាស់បំពានគ្រឿងញៀនត្រូវគិតគូរៀបចំទីកន្លែង សមស្រប សំរាប់ប្រមូលផ្តុំអ្នកញៀនគ្រឿងញៀននៅតាមស្នងការដ្ឋាននគរបាល និងបញ្ជាការដ្ឋានកងរាជ អាវុធហត្ថខេត្ត-ក្រុង ដើម្បីព្យាបាល និងអប់រំកែប្រែពួកគេអោយក្លាយជាពលរដ្ឋល្អរបស់សង្គមជាតិវិញ ។

៦. ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការជាមួយក្រសួង និងស្ថាប័នពាក់ព័ន្ធ ដើម្បីជំរុញការចងក្រង ឯកសារមេរៀនអប់រំផ្សព្វផ្សាយអំពីបញ្ហាគ្រឿងញៀន ដើម្បីបញ្ជ្រាបបញ្ចូលទៅក្នុងកម្មវិធីសិក្សាជាតិទាំងក្នុង និងក្រៅប្រព័ន្ធអប់រំចាប់ពីបឋមសិក្សារហូតដល់ឧត្តមសិក្សា ហើយត្រូវជំរុញគណៈកម្មការទប់ស្កាត់បាតុភាព អសកម្មក្នុងសាលារៀននិងគ្រឹះស្ថានសិក្សាដើម្បីទប់ស្កាត់ការជ្រៀតចូលពីសំណាក់ក្រុមជនខិលខូចដែលមក ញុះញង់អូសទាញសិស្ស និស្សិត ។

៧. ក្រសួងព័ត៌មាន ត្រូវមានកម្មវិធីផ្សព្វផ្សាយអោយបានទូលំទូលាយដើម្បីបង្កើនការយល់ដឹងពីគ្រឿង ញៀន និងគ្រោះថ្នាក់បណ្តាលពីការប្រើប្រាសគ្រឿងញៀនដល់សាធារណជនដោយបញ្ជ្រាបខ្លឹមសារក្នុងកម្មវិធី ផ្សព្វផ្សាយតាមគ្រប់រូបភាព និងគ្រប់ប្រព័ន្ធឃោសនារបស់ជាតិ និងឯកជន ។

៨. ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈត្រូវចូលរួមសកម្មភាពតាមរូបភាពសិល្បៈក្នុងការអប់រំមហាជន អោយមានការយល់ដឹងពីគ្រោះថ្នាក់នៃគ្រឿងញៀន និងណែនាំដល់ម្ចាស់រោងភាពយន្តរដ្ឋ និងឯកជនទាំងអស់ អោយរៀបចំបញ្ចាំងឯកសារផ្សព្វផ្សាយស្តីពីបញ្ហាគ្រឿងញៀនមួយឈុតខ្លីមុន និងបញ្ចាំងខ្សែភាពយន្ត ប្រចាំថ្ងៃរបស់ខ្លួន ។

៩. ក្រសួងធម្មការ និងសាសនាត្រូវណែនាំដល់មន្ទីរធម្មការខេត្ត-ក្រុង ដោយសហការជាមួយអាជ្ញាធរមូលដ្ឋានអោយខិតខំបំផុសព្រះសង្ឃតាមវត្តអារាម និងអង្គការសមាគមសាសនាអោយចូលរួមក្នុងសកម្មភាពអប់រំព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀនតាមរយៈសកម្មភាព សាសនា ។

១០. ក្រសួងកិច្ចការនារី មន្ទីរកិច្ចការនារីខេត្ត-ក្រុង ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋានដោយបង្កើន និង ពង្រីកការអប់រំដល់ស្ត្រី-កុមារជាពិសេសស្ត្រីជាមាតាអាណាព្យាបាលចូលរួមសកម្មភាពដើម្បីបង្ការទប់ស្កាត់ ការប្រើប្រាស់គ្រឿងញៀនក្នុងសង្គមគ្រួសារ និងសហគមន៍តាមរយៈការអនុវត្តផែនការនារីរតនៈរបស់ក្រសួង ។

១១. អាជ្ញាធរមូលដ្ឋានខេត្ត-ក្រុងត្រូវចុះធ្វើការណែនាំដល់អាជីវករ ម្ចាស់ផ្ទះសំណាក់សណ្ឋាគារភោជនីយដ្ឋាន ក្លឹបកំសាន្ត កន្លែងទស្សនីយភាព កន្លែងច្រៀងរាំដោយដាក់បំរាមហាមឃាត់ការប្រើប្រាស់បំពានគ្រឿងញៀនគ្រប់ប្រភេទ និងហាមយកកន្លែងខាងលើនេះធ្វើជាកន្លែងចែកចាយគ្រឿងញៀនខុសច្បាប់។ ក្នុងករណីមានការបំពានត្រូវអនុវត្តវិធានការច្បាប់ជាធរមាន ។

១២. អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន ត្រូវសម្រួលគ្រប់កិច្ចការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធ ផ្នែកឯកជនអង្គការអន្តរជាតិ និងសង្គមស៊ីវិលដើម្បីរៀបចំគោលនយោបាយរបស់រាជរដ្ឋាភិបាល ស្តីពីការអប់រំព្យាបាល និងស្តារនីតិសម្បទាអ្នកញៀនគ្រឿងញៀន និងវិធានការបង្ការទប់ស្កាត់ការរីរាលដាលជម្ងឺអេដស៍ ដែលបណ្តាលពីការប្រើបំពានគ្រឿងញៀនអោយសំរេចបានលទ្ធផលល្អ ។

ទទួលបានសារាចរនេះ ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរជាតិប្រឆាំងគ្រឿងញៀន និងអាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ត្រូវរៀបចំផែនការសកម្មភាពច្បាស់លាស់សំដៅធានាអនុវត្តខ្លឹមសារសារាចនេះ ឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ២៣ ខែ តុលា ឆ្នាំ ២០០៦

**នាយករដ្ឋមន្ត្រី**

**ហ៊ុន សែន**

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់សមាជិកអាជ្ញាជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន
- គ្រប់ក្រសួងស្ថាប័ន និងខេត្ត-ក្រុង
- ឯកសារ-កាលប្បវត្តិ